# អាជីវបរិសុទ្ធិសីល



## ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា
## នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា


*រៀបរៀងដោយ*

*ខ្ញុំព្រះករុណាខ្ញុំបាទ*

**កុល ផេង**


**ព.ស. ២៥៦៤**

# អាជីវបរិសុទ្ធិសីល

រៀបរៀងដោយ

*បណ្ឌិត* **គុល ផេង**

សីល សមាធិ បញ្ញា

**ការផ្សាយរបស់ពុទ្ធិកបណ្ឌិតសភា**

**នៃសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា**

**ព.ស. ២៥៦៤**

ឈ្មោះសៀវភៅ **អាជីវបរិសុទ្ធិសីល**


រៀបរៀងដោយ បណ្ឌិត **កុល ផេង**

ប្រធានពុទ្ធិកបណ្ឌិតសភា

នៃសាកលវិទ្យាល័យ

បញ្ញាសាស្ត្រកម្ពុជា



ទីតាំងធ្វើ ពុទ្ធិកបណ្ឌិតសភា

ការផ្សាយ របស់ពុទ្ធិកបណ្ឌិតសភា



រក្សាសិទ្ធិ ពុទ្ធិកបណ្ឌិតសភា



កាលបរិច្ឆេទ ថ្ងៃសៅរ៍ ១១ រោច ខែ

ស្រាពណ៍ ឆ្នាំជូត

ទោស័ក ព.ស. ២៥៦៤

ថ្ងៃទី ១៥ ខែ សីហា គ.ស.

២០២០

# អាជីវបរិសុទ្ធិសីល

**មាតិកា** **ទំព័រ**


ចូឡសីល ២៦........................................................ ២

មជ្ឈិមសីល ១០ .................................................... ៨

មហាសីល មាន ១៥៣ ......................................... ១០

  តិរច្ឆានវិជ្ជា ១៥៣ ........................................... ១០

ពុទ្ធបញ្ញត្តិ ........................................................... ៣៤

កុលទូសកកម្ម ៨ ............................................... ៣៧

បាបធម៌ ៥......................................................... ៣៨

អនេសនៈ ២១ ..................................................... ៣៩

សូចិមុខីសូត្រ...................................................... ៤៣

សតធម្មជាតក ..................................................... ៤៩

# អាជីវបរិសុទ្ធិសីល

**អាជីព** ( ន. ) [ --ជីប] or *អាជីវ ឬ អាជីវៈ (--ជីវៈ)* *( សំ., បា. )* ( អាជីវ, ខ្មែរប្រើផ្លាស់ វ ជា ព > អាជីព ) ដំណើរនៅមានជីវិត, ការនៅរស់; ការចិញ្ចឹមជីវិត, ដំណើរធ្វើការរបរចិញ្ចឹមជីវិត : *គាត់មានការលក់ដូរជាអាជីពរបស់គាត់, អ្នករកស៊ីដោយការបំបាត់ប្រវ័ញ្ចន៍ ឈ្មោះថាអ្នកមានអាជីវៈមិនបរិសុទ្ធ* ( មិច្ឆាជីវៈ ) ។

- *អាជីវកម្ម ការប្រកបមុខរបរចិញ្ចឹមជីវិត; ការចាត់ចែងធ្វើយកផលពីដំណាំ, ពីឈើព្រៃ, ពីព្រះធរណីជាដើម; ទីដីដែលគេប្រកបធ្វើការយកផលនោះ ៗ* : *ប្រកបអាជីវកម្មខាងឈើព្រៃ ។*

- *អាជីវករ ជនអ្នកប្រកបអាជីវកម្ម ។*

## អាជីវបរិសុទ្ធិសីល

- *អាជីវបារិសុទ្ធិ* (--ប៉ា--) *សេចក្តីបរិសុទ្ធ ព្រោះការចិញ្ចឹមជីវិតត្រឹមត្រូវ។*

- ***អាជីវបារិសុទ្ធិសីល*** (--ប៉ា--) *សីលរបស់បព្វជិតអ្នកមានសេចក្តីបរិសុទ្ធព្រោះការចិញ្ចឹមជីវិតត្រឹមត្រូវ* (*ម. ព. ចតុប្បារិសុទ្ធិសីល* ផង)។

## ចូឡសីល ២៦

១. **បាណាតិបាតា បដិវិរតោ** *វៀរស្រឡះចាកបាណាតិបាត*

២. **អទិន្នាទានា បដិវិរតោ** *វៀរស្រឡះចាកអទិន្នាទាន*

៣. **អាភចារី វិរតោ មេថុនា** *វៀរចាកមេថុនធម្មជាធម៌របស់អ្នកស្រុក*

## អាជីវបរិសុទ្ធិសីល

៤. មុសាវាទា បដិវិរតោ *វៀរស្រឡះចាកមុសាវាទ*

៥. បិសុណាយ វាចាយ បដិវិរតោ *វៀរស្រឡះចាកបិសុណាវាចា*

៦. ផរុសាយ វាចាយ បដិវិរតោ *វៀរស្រឡះចាកផរុសវាចា*

៧. សម្ផប្បលាបា បដិវិរតោ *វៀរស្រឡះចាកសម្ផប្បលាបៈ*

៨. ពីជគាមភូតគាមសមារម្ភា បដិវិរតោ *វៀរស្រឡះចាកការធ្វើពីជគាមនិងភូតគាម*

៩. រត្តូបរតោ វិរតោ វិកាលភោជនា *វៀរលែងបរិភោគក្នុងរាត្រី វៀរលែងបរិភោគក្នុង កាលខុស*

## អាជីវបរិសុទ្ធិសីល

**១០. នច្ចគីតវាទិតវិសូកទស្សនា បដិវិរតោ** *វៀរស្រឡះចាកកិរិយាមើលនូវរបាំ និងការស្តាប់នូវចម្រៀង និងភ្លេងប្រគំ ដែលជាសត្រូវដល់កុសលធម៌*

**១១. មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា បដិវិរតោ** *វៀរស្រឡះចាកកិរិយា ទ្រទ្រង់ប្រដាប់ស្អិតស្អាងរាងកាយដោយផ្កាកម្រង និងគ្រឿងក្រអូបនិងគ្រឿងលាបផ្សេងៗ*

**១២. ឧច្ចាសយនមហាសយនា បដិវិរតោ** *វៀរស្រឡះចាកទីដេកទីអង្គុយដ៏ខ្ពស់ និងទីដេកទីអង្គុយដ៏ប្រសើរ*

**១៣. ជាតរូបរជតបដិគ្គហណា បដិវិរតោ** *វៀរស្រឡះចាកកិរិយាទទួលមាសនិងប្រាក់*

## អាជីវបរិសុទ្ធិសីល

**១៤. អាមកធញ្ញបដិគ្គហណា បដិវិរតោ** *វៀរ*

*ស្រឡះចាកកិរិយាទទួលធញ្ញជាតឆៅ*

**១៥. អាមកមំសបដិគ្គហណា បដិវិរតោ** *វៀរ*

*ស្រឡះចាកកិរិយាទទួលសាច់ឆៅ*

**១៦. ឥត្ថិកុមារិកបដិគ្គហណា បដិវិរតោ** *វៀរ*

*ស្រឡះចាកកិរិយាទទួលស្រីនិងក្មេងស្រី*

**១៧. ទាសិទាសបដិគ្គហណា បដិវិរតោ** *វៀរ*

*ស្រឡះចាកកិរិយាទទួលខ្ញុំស្រីនិងខ្ញុំប្រុស*

**១៨. អជេឡកបដិគ្គហណា បដិវិរតោ** *វៀរ*

*ស្រឡះចាកកិរិយាទទួលពពែនិងចៀម*

**១៩. កុក្កុដសូករបដិគ្គហណា បដិវិរតោ** *វៀរ*

*ស្រឡះចាកកិរិយាទទួលមាន់និងជ្រូក*

# អាជីវបរិសុទ្ធិសីល

**២០. ហត្ថិគវស្សវឡវបដិគ្គហណា បដិវិរតោ** *វៀរស្រឡះចាកកិរិយាទទួលដំរី គោ សេះ ឈ្មោលញី*

**២១. ខេត្តវត្ថុបដិគ្គហណា បដិវិរតោ** *វៀរស្រឡះចាកកិរិយាទទួលស្រែនិងចម្ការ*

**២២. ទូតេយ្យបហិណគមនានុយោគា បដិ-វិរតោ** *វៀរស្រឡះចាកកិរិយាប្រកបនូវទូតកម្មគឺនាំសំបុត្រឬពាក្យបណ្ដាំដល់គ្រហស្ថនិងទៅដោយគេបញ្ជូនអំពីផ្ទះមួយទៅផ្ទះមួយ*

**២៣. កយវិក្កយា បដិវិរតោ** *វៀរស្រឡះចាកការទិញនិងការលក់*

**២៤. តុលាកូដកំសកូដមានកូដា បដិវិរតោ** *វៀរស្រឡះចាកការឆបោក ឬបន្លំដោយជញ្ជីង និងឆបោកដោយភាជន៍មាស ឆបោក ដោយរង្វាស់រង្វាល់*

# អាជីវបរិសុទ្ធិសីល

**២៥. ឧក្កោដនវញ្ចននិកតិសាចិយោគា បដិ-វិរតោ** *វៀរស្រឡះចាកកិរិយាប្រកបនូវអំពើវៀច គឺ ការបង្ខុសបំភាន់ បញ្ឆោតបោកប្រាស បន្លំដោយរបស់ ប្លម*

**២៦. ឆេទនវធពន្ធនវិបរាមោសអាលោប-សហសាការា បដិវិរតោ** *វៀរស្រឡះចាកកិរិយា កាត់ (នូវអវយវៈមានដៃជាដើម) និងការសម្លាប់ ចង ធ្វើមនុស្សឲ្យវង្វេងផ្លូវ ប្លន់អ្នកស្រុក កំហែងយកទ្រព្យ ។*

*(សុត្តន្តបិដក ទីឃនិកាយ សីលក្ខន្ធវគ្គ ព្រហ្មជាលសូត្រ)*

*ចូឡសីល ចប់ ។*

## អាជីវបរិសុទ្ធិសីល

## មជ្ឈិមសីល ១០

**១. ពីជគាមភូតគាមសមារម្ភា បដិវិរតោ** *វៀរស្រឡះចាកកិរិយាធ្វើពីជគាម និងភូតគាមឲ្យវិនាស*

**២. សន្និធិការបរិភោគា បដិវិរតោ** *វៀរស្រឡះចាកការបរិភោគវត្ថុដែលសន្សំទុក*

**៣. វិសូកទស្សនា បដិវិរតោ** *វៀរស្រឡះចាកកិរិយាស្ដាប់ និងការមើលល្បែង ដែលជាសត្រូវដល់កុសលធម៌*

**៤. ជូតប្បមាទដ្ឋានានុយោគា បដិវិរតោ** *វៀរស្រឡះចាកកិរិយាប្រកបរឿយៗ នូវល្បែងបាស្កាដែលជាហេតុជាទីតាំងនៃសេចក្ដីប្រមាទ*

**៥. ឧច្ចាសយនមហាសយនា បដិវិរតោ** *វៀរស្រឡះចាកឧច្ចាសយនមហាសយនៈ*

## អាជីវបរិសុទ្ធិសីល

**៦. មណ្ឌានវិក្ខសនដ្ឋាជានុយោគា បដិវិរតោ** *វៀរស្រឡះចាកការប្រកបរឿយៗ នូវវត្ថុជាទីតាំងនៃការប្រដាប់ស្អិតស្អាងរាងកាយ*

**៧. តិរច្ឆានកថាយ បដិវិរតោ** *វៀរស្រឡះចាកតិរច្ឆានកថា*

**៨. វិគ្គាហិកកថាយ បដិវិរតោ** *វៀរស្រឡះហើយចាកពាក្យពោលប្រណាំងប្រជែង*

**៩. ទូតេយ្យបហិណគមជានុយោគា បដិវិរតោ** *វៀរស្រឡះហើយចាកការប្រកបនូវទូតកម្មគឺនាំសំបុត្រ ឬពាក្យបណ្ដាំនៃគ្រហស្ថ ឬទៅដោយគេបញ្ជូនអំពីផ្ទះមួយទៅផ្ទះមួយ*

**១០. កុហានលបនា បដិវិរតោ** *វៀរស្រឡះហើយចាកការកុហក និងពាក្យរាក់ទាក់ ។*

(*សុត្តន្តបិដក ទីឃនិកាយ សីលក្ខន្ធវគ្គ ព្រហ្មជាលសូត្រ*)

*មជ្ឈិមសីល ចប់ ។*

## អាជីវបរិសុទ្ធិសីល

# មហាសីល មាន ១៥៣

# (ដោយការវៀរចាកតិរច្ឆានវិជ្ជា)

**តិរច្ឆានវិជ្ជាយ មិច្ឆាជីវា បដិវិរតោ** *វៀរស្រឡះចាកមិច្ឆាជីវៈព្រោះតិរច្ឆានវិជ្ជា (ទាំង១៥៣)* ។

## តិរច្ឆានវិជ្ជា ១៥៣

### អង្គវគ្គ

១. **អង្គំ** *ការទាយអវយវៈ*

២. **និមិត្តំ** *ទាយនិមិត្ត (ហេតុ)*

៣. **ឧប្បាតំ** *ទាយឧត្បាត គឺធ្លាក់ចុះនៃហេតុធំៗ មានរន្ទះបាញ់ ជាដើម*

៤. **សុបិនំ** *ទាយយល់សប្តិ*

# **អាជីវបរិសុទ្ធិសីល**

៥. **លក្ខណំ** *ទាយលក្ខណៈ*

៦. **មូសិកច្ឆិន្នំ** *ទាយវត្ថុមានសំពត់ជាដើមដែលកណ្ដុរកាត់*

៧. **អគ្គិហោមំ** *និយាយអំពីការបូជាដោយភ្លើង*

៨. **ទព្វិហោមំ** *និយាយអំពីការបូជាដោយវែក*

៩. **ថុសហោមំ** *និយាយអំពីការបូជាដោយអង្កាម*

១០. **កណហោមំ** *និយាយអំពីការបូជាដោយកុណ្ឌក: (កន្ទក់)*

១១. **តណ្ឌុលហោមំ** *និយាយអំពីការបូជាដោយអង្ករ*

## **អាជីវបរិសុទ្ធិសីល**

១២. **សប្បិហោមំ** *និយាយអំពីការបូជាដោយទឹកដោះរាវ*

១៣. **តេលហោមំ** *និយាយអំពីការបូជាដោយប្រេង*

១៤. **មុខហោមំ** *និយាយអំពីការបូជាដោយមាត់*

១៥. **លោហិតហោមំ** *និយាយអំពីការបូជាដោយឈាម*

១៦. **អង្គវិជ្ជា** *វិជ្ជាសម្រាប់ទាយអវយវៈ*

១៧. **វត្ថុវិជ្ជា** *វិជ្ជាសម្រាប់ទាយទីភូមិឋាន (ថាឲ្យទុក្ខឲ្យសុខ)*

១៨. **ខត្តវិជ្ជា** *វិជ្ជាសម្រាប់ទាយទីស្រែចម្ការ*

## អាជីវបរិសុទ្ធិសីល

១៩. សិវវិជ្ជា វិជ្ជាស្គាល់ព្រៃខ្មោច

២០. ភូតវិជ្ជា វិជ្ជាចាប់ខ្មោច

២១. ភូរិវិជ្ជា វិជ្ជាសម្រាប់ការពាររក្សាភូមិផ្ទះ

២២. អហិវិជ្ជា វិជ្ជាស្តោះពស់

២៣. វិសវិជ្ជា វិជ្ជារក្សាពិស

២៤. វិច្ឆិកវិជ្ជា វិជ្ជាស្តោះខ្ទួយទិច

២៥. មូសិកវិជ្ជា វិជ្ជាស្តោះកណ្តុរខាំ

២៦. សកុណវិជ្ជា វិជ្ជាសម្រាប់ទាយសម្រែកសត្វស្លាប

២៧. វាយសវិជ្ជា វិជ្ជាសម្រាប់ទាយសម្រែកក្អែក

## **អាជីវបរិសុទ្ធិសីល**

**២៨. បក្ខជ្ឈានធំ** *វិជ្ជាសម្រាប់ទាយអាយុ*

**២៩. សរបរិត្តាណំ** *វិជ្ជាសម្រាប់ការពំងសរ*

**៣០. មិគចក្កំ** *វិជ្ជាសម្រាប់មើលនូវស្នាមជើងម្រឹគ គឺសត្វជើង ៤ ទាំងអស់ ។*

## **មណិលក្ខណវគ្គ**

**៣១. មណិលក្ខណំ** *ការទាយលក្ខណៈកែវមណី*

**៣២. វត្ថលក្ខណំ** *ទាយលក្ខណៈសំពត់*

**៣៣. ទណ្ឌលក្ខណំ** *ទាយលក្ខណៈដំបង ឬឈើច្រត់*

**៣៤. សត្ថលក្ខណំ** *ទាយលក្ខណៈសស្ត្រា*

# អាជីវបរិសុទ្ធិសីល

៣៥. អសិលក្ខណំ *ទាយលក្ខណៈដាវ*

៣៦. ឧសុលក្ខណំ *ទាយលក្ខណៈសរ*

៣៧. ធនុលក្ខណំ *ទាយលក្ខណៈធ្នូ*

៣៨. អាវុធលក្ខណំ *ទាយលក្ខណៈអាវុធ*

៣៩. ឥត្ថិលក្ខណំ *ទាយលក្ខណៈស្រី*

៤០. បុរិសលក្ខណំ *ទាយលក្ខណៈប្រុស*

៤១. កុមារលក្ខណំ *ទាយលក្ខណៈក្មេងប្រុស*

៤២. កុមារិលក្ខណំ *ទាយលក្ខណៈក្មេងស្រី*

៤៣. ទាសលក្ខណំ *ទាយលក្ខណៈខ្ញុំប្រុស*

៤៤. ទាសិលក្ខណំ *ទាយលក្ខណៈខ្ញុំស្រី*

# អាជីវបរិសុទ្ធិសីល

៤៥. ហត្ថិលក្ខណំ *ទាយលក្ខណៈដំរី*

៤៦. អស្សលក្ខណំ *ទាយលក្ខណៈសេះ*

៤៧. មហឹសលក្ខណំ *ទាយលក្ខណៈក្របី*

៤៨. ឧសភលក្ខណំ *ទាយលក្ខណៈគោឧសភៈ*

៤៩. គោលក្ខណំ *ទាយលក្ខណៈគោ*

៥០. អជលក្ខណំ *ទាយលក្ខណៈពពែ*

៥១. មេណ្ឌលក្ខណំ *ទាយលក្ខណៈកែះ*

៥២. កុក្កុដលក្ខណំ *ទាយលក្ខណៈមាន់*

៥៣. វដ្ដកលក្ខណំ *ទាយលក្ខណៈចាបឬក្រួច*

៥៤. គោធាលក្ខណំ *ទាយលក្ខណៈទន្សង*

## **អាជីវបរិសុទ្ធិសីល**

**៥៥. កណ្ណិកាលក្ខណំ** *ទាយលក្ខណៈគ្រឿងប្រដាប់ឬកំពូលផ្ទះ*

**៥៦. កច្ឆបលក្ខណំ** *ទាយលក្ខណៈអណ្តើក*

**៥៧. មិគលក្ខណំ** *ទាយលក្ខណៈម្រឹគ ។*

## **រញ្ញោវគ្គ**

**៥៨. រញ្ញំ និយ្យានំ ភវិស្សតិ** *ទាយការលើកទ័ពថាព្រះរាជាគួរស្តេចចេញទៅ (ក្នុងថ្ងៃនោះ)*

**៥៩. រញ្ញំ អនិយ្យានំ ភវិស្សតិ** *ព្រះរាជាគួរស្តេចចូលមកវិញ (ក្នុងថ្ងៃនោះ)*

**៦០. អព្ភន្តរានំ រញ្ញំ ឧបយានំ ភវិស្សតិ** *ព្រះរាជាខាងក្នុងនឹងរុករានចូលទៅ*

## អាជីវបរិសុទ្ធិសីល

៦១. ពាហិរកធំ រញ្ជួំ អបយាធំ កវិស្សតិ *ព្រះរាជាខាងក្រៅនឹងថយចេញទៅ*

៦២. ពាហិរកធំ រញ្ជួំ ឧបយាធំ កវិស្សតិ *ព្រះរាជាខាងក្រៅនឹងរុករានចូលមក*

៦៣. អព្ភន្តរកធំ រញ្ជួំ អបយាធំ កវិស្សតិ *ព្រះរាជាខាងក្នុងនឹងថយចេញទៅ*

៦៤. អព្ភន្តរកធំ រញ្ជួំ ជយោ កវិស្សតិ *ព្រះរាជាខាងក្នុងនឹងមានជ័យជម្នះ*

៦៥. ពាហិរកធំ រញ្ជួំ បរាជយោ កវិស្សតិ *ព្រះរាជាខាងក្រៅនឹងបរាជ័យ*

៦៦. ពាហិរកធំ រញ្ជួំ ជយោ កវិស្សតិ *ព្រះរាជាខាងក្រៅ នឹងមានជ័យជម្នះ*

## **អាជីវបរិសុទ្ធិសីល**

**៦៧. អត្ថុត្តរាជំ រញ្ញោ បរាជយោ ភវិស្សតិ** *ព្រះរាជាខាងក្នុងនឹងបរាជ័យ*

**៦៨. ឥតិ ឥមស្ស ជយោ ភវិស្សតិ** *ព្រះរាជាអង្គនេះនឹងមានជ័យជម្នះ*

**៦៩. ឥមស្ស បរាជយោ ភវិស្សតិ** *ឯព្រះរាជាអង្គនេះនឹងបរាជ័យ ។*

## **ចន្ទគ្គាហាទគ្គ**

**៧០. ចន្ទគ្គាហោ ភវិស្សតិ** *ការទាយថា (ក្នុងថ្ងៃឯណោះ) នឹងមានចន្ទ្រគ្រាះ*

**៧១. សូរិយគ្គាហោ ភវិស្សតិ** *ការទាយថា (ក្នុងថ្ងៃឯណោះ) នឹងមានសូរ្យគ្រាះ*

## **អាជីវបរិសុទ្ធិសីល**

**៧២. ឆត្តត្តគ្គាហោ កវិស្សតិ** *ការទាយថា (ក្នុងថ្ងៃឯណោះ) នឹងមាននក្សត្រគ្រោះ គឺផ្កាយព្រះគ្រោះដើររួមចូលគ្នា ឬដើររំលងព្រះអាទិត្យព្រះចន្ទ្រ ឬផ្កាយណាមួយ*

**៧៣. ចន្ទិមសូរិយានំ បថគមនំ កវិស្សតិ** *ព្រះចន្ទ្រព្រះអាទិត្យនឹងដើរតាមផ្លូវត្រូវគ្នា*

**៧៤. ចន្ទិមសូរិយានំ ឧប្បថគមនំ កវិស្សតិ** *ព្រះចន្ទ្រព្រះអាទិត្យនឹងដើរខុសផ្លូវគ្នា*

**៧៥. ឆត្តត្តានំ បថគមនំ កវិស្សតិ** *ផ្កាយទាំងឡាយនឹងដើរតាមផ្លូវត្រូវគ្នា*

**៧៦. ឆត្តត្តានំ ឧប្បថគមនំ កវិស្សតិ** *ផ្កាយទាំងឡាយនឹងដើរខុសផ្លូវគ្នា*

## **អាជីវបរិសុទ្ធិសីល**

**៧៧. ឧក្កាបាតោ ភវិស្សតិ** *នឹងមានឧក្កាបាត*

**៧៨. ទិសាឌាហោ ភវិស្សតិ** *នឹងកើតមានកម្តៅក្នុងទិស*

**៧៩. ភូមិចាលោ ភវិស្សតិ** *នឹងមានកម្រើកផែនដី*

**៨០. ទេវទុន្ទុភិ ភវិស្សតិ** *នឹងមានផ្គរលាន់ (ឥតមានភ្លៀង)*

**៨១. ចន្ទិមសូរិយនក្ខត្តានំ ឧគ្គមនំ ឱគមនំ សំកិលេសំ វោទានំ ភវិស្សតិ** *ព្រះចន្ទ្រ ព្រះអាទិត្យ ផ្កាយនឹងរះឡើង ឬអស្តង្គតទៅវិញ នឹងសៅហ្មង ឬផូរផង់*

# **អាជីវបរិសុទ្ធិសីល**

**៨២. ឃរិីចាកោ ចន្ទគ្គាហោ ភវិស្សតិ** *ចន្ទ្រគ្រាះ នឹងបណ្ដាលឲ្យបានសុខទុក្ខយ៉ាងនេះ (ដល់សត្វលោក)*

**៨៣. ឃរិីចាកោ សូរិយគ្គាហោ ភវិស្សតិ** *សូរ្យគ្រាះនឹងបណ្ដាលឲ្យមានសុខទុក្ខយ៉ាងនេះ*

**៨៤. ឃរិីចាកោ នក្ខត្តគ្គាហោ ភវិស្សតិ** *នក្សត្រគ្រាះនឹងបណ្ដាលឲ្យមានសុខទុក្ខយ៉ាងនេះ*

**៨៥. ឃរិីចាកំ ចន្ទិមសូរិយានំ បថគមនំ ភវិស្សតិ** *ព្រះចន្ទ្រនិងព្រះអាទិត្យ ដើរតាមផ្លូវត្រូវគ្នា នឹងបណ្ដាលឲ្យមានសុខ ទុក្ខយ៉ាងនេះ*

# អាជីវបរិសុទ្ធិសីល

**៨៦. ឃរីរិចាកាំ ចង្កិមសូរិយាធំ ឧប្បជគមធំ កវិស្សតិ** *ព្រះចន្ទ្រនិងព្រះអាទិត្យ ដើរខុសផ្លូវគ្នា នឹងបណ្តាលឲ្យមានសុខទុក្ខ យ៉ាងនេះ*

**៨៧. ឃរីរិចាកាំ ឯក្ខត្តាធំ បជគមធំ កវិស្សតិ** *ពួកផ្កាយ ដើរតាមផ្លូវត្រូវគ្នា នឹងបណ្តាលឲ្យមានសុខទុក្ខយ៉ាងនេះ*

**៨៨. ឃរីរិចាកាំ ឯក្ខត្តាធំ ឧប្បជគមធំ កវិស្សតិ** *ពួកផ្កាយ ដើរខុសផ្លូវគ្នា នឹងបណ្តាលឲ្យមានសុខទុក្ខ យ៉ាងនេះ*

**៨៩. ឃរីរិចាគោ ឧក្កាចាតោ កវិស្សតិ** *ឧក្កាបាត នឹងបណ្តាល ឲ្យមានទុក្ខសុខយ៉ាងនេះ*

# អាជីវបរិសុទ្ធិសីល

៩០. **ឯវំវិបាកោ ទិសាឌាហោ ភវិស្សតិ** *កម្ដៅក្នុងទិស នឹងបណ្ដាលឲ្យមានសុខទុក្ខយ៉ាងនេះ*

៩១. **ឯវំវិបាកោ ភូមិចាលោ ភវិស្សតិ** *ការកម្រើកផែនដី នឹងបណ្ដាលឲ្យមានសុខទុក្ខយ៉ាងនេះ*

៩២. **ឯវំវិបាកោ ទេវទុទ្រភិ ភវិស្សតិ** *ផ្គរលាន់ (ឥតមានភ្លៀង) នឹង បណ្ដាលឲ្យមានសុខទុក្ខយ៉ាងនេះ*

៩៣. **ឯវំវិបាកំ ចន្ទិមសូរិយនក្ខត្តានំ ឧគ្គមនំ ឱគមនំ សំកិលេសំ វោទានំ ភវិស្សតិ** *ព្រះចន្ទ្រ ព្រះអាទិត្យនិងផ្កាយរះឡើង ឬអស្ដង្គត ទៅវិញ សៅហ្មងឬផូរផង់ នឹងបណ្ដាលឲ្យមានសុខទុក្ខយ៉ាងនេះ ។*

# **អាជីវបរិសុទ្ធិសីល**

## **សុខុដ្ឋិកវគ្គ**

**៩៤. សុវុដ្ឋិកា កវិស្សតិ** *ការទាយថា (ក្នុងឆ្នាំនេះ) ភ្លៀងស្រួល*

**៩៥. ទុព្ពុដ្ឋិកា កវិស្សតិ** *ការទាយថា (ក្នុងឆ្នាំនេះ) នឹងមានភ្លៀងធ្លាក់មិនស្រួល*

**៩៦. សុភិក្ខំ កវិស្សតិ** *ការទាយថា (ក្នុងឆ្នាំនេះ) នឹងមានបាយសម្បូណ៌*

**៩៧. ទុព្ភិក្ខំ កវិស្សតិ** *ការទាយថា (ក្នុងឆ្នាំនេះ) នឹងមានបាយក្រ*

**៩៨. ខេមំ កវិស្សតិ** *ការទាយថា (ក្នុងឆ្នាំនេះ) នឹងមានសេចក្ដីក្សេមក្សាន្ត*

## **អាជីវបរិសុទ្ធិសីល**

**៩៩. កយំ កវិស្សតិ** *ការទាយថា (ក្នុងឆ្នាំនេះ) នឹងមានភ័យ*

**១០០. រោគោ កវិស្សតិ** *ការទាយថា (ក្នុងឆ្នាំនេះ) នឹងមានរោគ*

**១០១. អារោគ្យំ កវិស្សតិ** *ការទាយថា (ក្នុងឆ្នាំនេះ) នឹងមិនមានរោគ*

**១០២. មុទ្ទា** *ការរាប់ដោយដៃទទេ*

**១០៣. គណនា** *ការរាប់ដោយវិធីនព្វន្ត*

**១០៤. សង្ខានំ** *រាប់បូក*

**១០៥. កាវេយ្យំ** *កាព្យឃ្លោង (តែងកាព្យដើម្បីចិញ្ចឹមជីវិត)*

## អាជីវបរិសុទ្ធិសីល

១០៦. លោកាយតំ *គម្ពីរលោកាយតៈ។*

## អាវាហនវគ្គ

១០៧. អាវាហនំ *វិធីរៀបអាវាហមង្គល*

១០៨. វិវាហនំ *វិធីរៀបវិវាហមង្គល*

១០៩. សំវរណំ *វិធីធ្វើឲ្យព្រមព្រៀងគ្នា* (*ស្នេហ៍*)

១១០. វិវរណំ *វិធីធ្វើឲ្យព្រាត់ប្រាសគ្នា*

(*បង់ចំណែង*)

១១១. សំកិរណំ *វិធីប្រមូលទ្រព្យ*

១១២. វិកិរណំ *វិធីប្រកបជំនួញ*

# អាជីវបរិសុទ្ធិសីល

**១១៣. សុភគករណំ** *វិធីធ្វើឲ្យចូលចិត្តស្រឡាញ់គ្នា ឬធ្វើឲ្យមានសិរី*

**១១៤. ទុព្ភគករណំ** *វិធីធ្វើឲ្យស្អប់គ្នា*

**១១៥. វិរុទ្ធគព្ភករណំ** *វិធីធ្វើគភ៌ដែលបំរុងនឹងវិនាសមិនឲ្យវិនាស*

**១១៦. ជិវ្ហានិពន្ធនំ** *វិធីចងអណ្តាតឲ្យរឹងដោយមន្ត*

**១១៧. ហនុសំហននំ** *វិធីចងចង្កាឲ្យរឹង*

**១១៨. ហត្ថាភិជប្បនំ** *វិធីសូត្ររបៀនដើម្បីមិនឲ្យពុសំឡេងដោយដៃ*

**១១៩. ហនុជប្បនំ** *វិធីសូត្ររបៀនដើម្បីមិនឲ្យពុសំឡេងដោយចង្កា*

## **អាជីវបរិសុទ្ធិសីល**

**១២០. កណ្ណជប្បធំ** *វិធីសូត្ររៀនដើម្បីមិនឲ្យឮសំឡេងដោយត្រចៀក*

**១២១. អាទាសបញ្ហាំ** *ប្រស្នាកញ្ចក់ គឺមន្តខាបយកទេវតាឲ្យមកនៅនឹងកញ្ចក់ ហើយសួរប្រស្នា*

**១២២. កុមារិកបញ្ហាំ** *ប្រស្នាកុមារី គឺមន្តបញ្ចូលទេវតាក្នុងសរីរៈនៃកុមារីហើយសួរប្រស្នា*

**១២៣. ទេវបញ្ហាំ** *ប្រស្នាទេវតា គឺមន្តបញ្ចូលទេវតាក្នុងសរីរៈនៃទាសី ហើយសួរប្រស្នា*

**១២៤. អាទិច្ចុបដ្ឋានធំ** *វិធីបម្រើព្រះអាទិត្យ*

**១២៥. មហាតុបដ្ឋានធំ** *វិធីបម្រើមហាព្រហ្ម*

## អាជីវបរិសុទ្ធិសីល

១២៦. **អគ្គុជ្ជលធំ** *វិធីបញ្ចេញភ្លើងអំពីមាត់ដោយមន្ត*

១២៧. **សិរិវ្ហាយធំ** *វិធីហៅសិរីឲ្យមកបិតក្នុងសរីរៈ ។*

## សន្តិកម្មវគ្គ

១២៨. **សន្តិកម្មំ** *ការបន់ស្រន់*

១២៩. **បណិធិកម្មំ** *លាបំណន់*

១៣០. **ភូតកម្មំ** *ធ្វើមន្តសម្រាប់ការពារបិសាច*

១៣១. **ភូរិកម្មំ** *ធ្វើមន្តសម្រាប់ការពារផ្ទះ*

១៣២. **វស្សកម្មំ** *ធ្វើខ្ទើយឲ្យដូចជាប្រុស*

១៣៣. **វោស្សកម្មំ** *ធ្វើប្រុសឲ្យដូចជាខ្ទើយគឺក្រៀវ*

## **អាជីវបរិសុទ្ធិសីល**

**១៣៤. វត្ថុកម្មំ** *ធ្វើពិធីសង់ផ្ទះលើទីដី ដែលមិនធ្លាប់បានធ្វើ*

**១៣៥. វត្ថុបរិកម្មំ** *ធ្វើពលិកម្មនៅទីដីសង់ផ្ទះ*

**១៣៦. អាចមនំ** *ជម្រះមុខឲ្យស្អាតដោយទឹកឲ្យគេ*

**១៣៧. ន្ហាបនំ** *ស្រោចទឹកបង្ហក់ប្រសិទ្ធីឲ្យគេ*

**១៣៨. ជុហានំ** *បូជាភ្លើងឲ្យគេ*

**១៣៩. វមនំ** *ផ្សំថ្នាំសម្រាប់ឲ្យក្អួត*

**១៤០. វិរេចនំ** *ផ្សំថ្នាំបញ្ចុះ*

**១៤១. ឧទ្ធំវិរេចនំ** *ផ្សំថ្នាំកម្ចាត់បង់នូវទោសខាងលើ*

**១៤២. អធោវិរេចនំ** *ផ្សំថ្នាំកម្ចាត់បង់នូវទោសខាងក្រោម*

# **អាជីវបរិសុទ្ធិសីល**

១៤៣. **សីសវិរេចនំ** *ផ្សំថ្នាំកម្ចាត់បង់នូវទោសក្នុងក្បាល*

១៤៤. **កណ្ណាតេលំ** *ស្ងួប្រេងសម្រាប់បន្តក់ត្រចៀក*

១៤៥. **នេត្តតប្បនំ** *ស្ងួប្រេងសម្រាប់ស្អំភ្នែក*

១៤៦. **នត្ថុកម្មំ** *ផ្សំថ្នាំសម្រាប់ហិត*

១៤៧. **អញ្ជនំ** *ផ្សំថ្នាំសម្រាប់លាបបង្កាត់*

១៤៨. **បច្ចញ្ជនំ** *ផ្សំថ្នាំត្រជាក់សម្រាប់លាបស្រលាប*

១៤៩. **សាលាកិយំ** *ធ្វើវេជ្ជកម្មរក្សាភ្នែក*

១៥០. **សល្លកត្តិយំ** *ធ្វើកម្មរបស់ពេទ្យ*

១៥១. **ទារកតិកិច្ឆា** *ធ្វើពេទ្យរក្សាកូនក្មេង*

## **អាជីវបរិសុទ្ធិសីល**

**១៨២. មូលភេសជ្ជធំ អនុប្បទានធំ** *ដាក់ថ្នាំក្រោយឲ្យជួយកម្លាំងថ្នាំមុន*

**១៨៣. ឱសថធំ បដិមោក្ខា** *លាងថ្នាំដើមចេញ ។*

(*សុត្តន្តបិដក ទីឃនិកាយ សីលក្ខន្ធវគ្គ ព្រហ្មជាលសូត្រ មហាសីល*)

*មហាសីល និងតិរច្ឆានវិជ្ជា ចប់ ។*

# អាជីវបរិសុទ្ធិសីល

## ពុទ្ធបញ្ញត្តិ

យា បន ភិក្ខុនី តិរច្ឆានវិជ្ជំ បរិយាបុណេ-យ្យ ចាចិត្តិយំ *ភិក្ខុនីណាមួយរៀនតិរច្ឆានវិជ្ជា ភិក្ខុនីនោះ ត្រូវអាបត្តិបាចិត្តិយៈ ។*

តិរច្ឆានវិជ្ជា ឯាម យង្កិញ្ចិ ពាហិរកំ អនត្ថ-សញ្ហិតំ *ចំណេះណាមួយជាខាងក្រៅ ដែលមិនប្រកបដោយប្រយោជន៍ ចំណេះនោះ ឈ្មោះថា* ***តិរច្ឆានវិជ្ជា*** *។*

*(បាចិត្តិយកណ្ឌ ចិត្តាគារវគ្គ តិរច្ឆានវិជ្ជាបរិយាបុណនសិក្ខាបទ)*

ន ភិក្ខវេ តិរច្ឆានវិជ្ជា បរិយាបុណិតព្វា យោ បរិយាបុណេយ្យ អាបត្តិ ទុក្កដស្ស *ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវរៀនតិរច្ឆានវិជ្ជាទេ ភិក្ខុណារៀន ត្រូវអាបត្តិទុក្កដ ។*

*(វិនយបិដក ចូឡវគ្គ ខុទ្ទកវត្ថុក្ខន្ធកៈ)*

# អាជីវបរិសុទ្ធិសីល

**ពាហិរកំ អនត្ថសំហិតន្តិ** ហត្ថិអស្សរថ-ធនុថរុសិប្បអាថព្វណខីលនវសីករណសោសាបនមន្តាគទប្បយោគាទិភេទំ បរូបឃាត-ករំ។

*ពីរបទថា* ***ពាហិរកំ អនត្ថសំហិតំ (ចំណេះណាមួយជាខាងក្រៅ ដែលមិនប្រកបដោយប្រយោជន៍)*** *បានដល់ សិប្បវិទ្យាការដែលចូលទៅសម្លាប់ បៀតបៀនអ្នកដទៃ មានប្រភេទដូចវិជ្ជាដែលប្រកបដោយដំរី សេះ រថ ធ្នូ និងដាវ និងមន្តអាថព្វណ (អាថាន់) មន្តកប់រូបទីងមោង មន្តធ្វើឲ្យមានអំណាច មន្តធ្វើឲ្យស្គម និងវិជ្ជាប្រកបដោយថ្នាំពិសជាដើម ។*

**បរិត្តន្តិ** យក្ខបរិត្តនាគមណ្ឌលាទិភេទំ សព្វម្បិ វដ្ដតិ។

# អាជីវបរិសុទ្ធិសីល

*ពាក្យថា* ***បរិត្តំ (វិជ្ជាការពារខ្លួន)*** *បានដល់ សូម្បីវិជ្ជាការពារខ្លួនគ្រប់យ៉ាង មានប្រភេទវិជ្ជាការពារពួកយក្ស ការពារពួកនាគ (ពស់) ជាដើម រមែងគួរ (រៀនបានមិនត្រូវអាបត្តិ) ។*

(*សមន្តបាសាទិកា អដ្ឋកថា វិនយបិដក*)

# អាជីវបរិសុទ្ធិសីល

# កុលទូសកកម្ម ៨

១. **បុប្ផទានំ** *ការឲ្យផ្កាឈើ*

២. **ផលទានំ** *ការឲ្យផ្លែឈើ*

៣. **ចុណ្ណទានំ** *ការឲ្យគ្រឿងលម្អិត*

៤. **មត្តិកាទានំ** *ការឲ្យដីស្អិត*

៥. **ទន្តកដ្ឋទានំ** *ការឲ្យឈើស្ទន់*

៦. **វេឡុទានំ** *ការឲ្យឫស្សី*

៧. **បណ្ណទានំ** *ការឲ្យស្លឹកឈើ*

៨. **ជង្ឃបេសនិកាំ** *ការបម្រើត្រកូលដោយកម្លាំងស្មង*

*(វិនយាលង្ការដីកា កុលសង្គហវិនិច្ឆយកថា)*

# អាជីវបរិសុទ្ធិសីល

## បាបធម៌ ៥

បាបធម៌ (សំ.), (បា.) (បាប៉ៈធ័រ) (បាបធម្ម) ធម៌លាមក, អាក្រក់ គឺសភាវៈដែលជាជំនួយចិត្ត នាំចិត្តឲ្យហ៊ានធ្វើអំពើអាក្រក់ ដូចយ៉ាងសេចក្ដីប្រណែនឈ្នានីស, ឥតអៀនខ្មាស ឥតរាងរអាទៅរកអំពើអាក្រក់ ជាដើម ។

**បាបធម៌ ៥ នោះគឺ ៖**

1. **កុហនា** ការកុហកដោយឫកពា ។
2. **លបនា** ការនិយាយពាក់ទាក់ដោយវាចា ។
3. **នេមិត្តិកតា** ការធ្វើនិមិត្ត គឺប្រើឧបាយកលដោយកាយខ្លះ ដោយវាចាខ្លះ ។
4. **និប្បេសិកតា** ការពោលគំរាម ឬសង្កត់ប្រើសំដីជាខ្នោសសម្រាប់កោសយកលាភ ។
5. **លាភេន លាភំ និជិគីសនតា** ការរកលាភដោយលាភ គឺការយកលាភទៅទាក់លាភ ។

(វិសុទ្ធិមគ្គ សីលនិទ្ទេស សីលប្បភេទកថា ចតុត្ថចតុក្ក)

# អាជីវបរិសុទ្ធិសីល

# អនេសនៈ ២១

*អនេសនៈ (បា.)(អៈនេសៈន័ៈ)(--នា < អន៑ "មិន, ពុំ, ឥត" + ឯសនា "ការស្វែង, ការស្វះស្វែង, ការរក") ការស្វែងរកពុំត្រូវតាមធម៌ឬពុំត្រូវតាមបែបបទ : កុំចិញ្ចឹមជីវិតដោយអនេសនៈ ។ ការចិញ្ចឹមជីវិតដោយដំណើរស្វែងរកចតុប្បច្ច័យ មិនត្រូវតាមធម៌វិន័យ : បព្វជិតពុទ្ធសាសនិកត្រូវវៀរចាកអនេសនៈ ២១ និង* [*បាបធម៌*]() *៥ (ព. វិ. ពុ.) ។ បើរៀងភ្ជាប់ពីខាងដើមសព្ទដទៃសរសេរជា អនេសន, ដូចជា អនេសនប្បហាន (--ន៉ាប់-ប៉ៈ--) ការលះអនេសនៈ គឺការស្វែងរកត្រូវតាមធម៌ ។ល។ អនេសនា (អៈនេសៈន៉ា)*

*ភិក្ខុគ្រប់រូបមិនត្រូវប្រព្រឹត្តអនេសនៈ ចំពោះគ្រហស្ថទាំងឡាយ ពោលគឺមិនត្រូវផ្ដល់វត្ថុអ្វីមួយដោយរំពឹងចង់បានលាភសក្ការៈពីពុទ្ធបរិស័ទវិញឡើយ ។ អានេសនៈ ២១ ប្រការនោះ គឺ ៖*

# អាជីវបរិសុទ្ធិសីល

១. វេឡុទានំ *ការឲ្យឫស្សី*

២. បត្តទានំ *ការឲ្យស្លឹកឈើ*

៣. បុប្ផទានំ *ការឲ្យផ្កាឈើ*

៤. ផលទានំ *ការឲ្យផ្លែឈើ*

៥. សិនាទានំ *ការឲ្យវត្ថុសម្រាប់ជូត*

៦. មត្តិកាទានំ *ការឲ្យដីស្អិត*

៧. ចុណ្ណទានំ *ការឲ្យគ្រឿងលម្អិត*

៨. ទន្តកដ្ឋទានំ *ការឲ្យឈើស្ទន់*

៩. មុខោទកទានំ *ការឲ្យទឹកលុបមុខ*

## អាជីវបរិសុទ្ធិសីល

**១០. ចាតុកម្យតា** *ការប្រព្រឹត្តបន្ទាបបន្ទន់កាយវាចា*

**១១. មុគ្គសូប្យតា** *ការពោលពាក្យពិតខ្លះ មិនពិតខ្លះ ដូចជាសម្លសណ្ដោកបាយ*

**១២. ចារិកត្យតា** *ការផ្គាប់ផ្គុនត្រកូល*

**១៣. ជង្ឃបេសនិយំ** *ការបម្រើត្រកូលដោយកម្លាំងស្មង*

**១៤. វេជ្ជកម្មំ** *ការធ្វើពេទ្យព្យាបាលជំងឺ*

**១៥. ទូតកម្មំ** *ការធ្វើទូត (នាំដំណឹងរបស់ត្រកូល)*

**១៦. បហិណគមនំ** *ការទទួលខ្លួនជាអ្នកបម្រើត្រកូលឲ្យគេប្រើទៅមក (ក្រៅអំពីការនាំដំណឹង)*

## **អាជីវបរិសុទ្ធិសីល**

**១៧. បិណ្ឌាបដិបិណ្ឌំ** *ការឲ្យចង្ហាន់បិណ្ឌបាតដល់ត្រកូលហើយស្វែងរកបរិភោគខ្លួនឯងជាខាងក្រោយ*

**១៨. ទាជាន្ទុប្បទានំ** *ការឲ្យទៅឲ្យមក*

**១៩. វត្ថុវិជ្ជា** *វិជ្ជាធ្វើជាគ្រូមើលទឹកដីជ័យភូមិ*

**២០. នក្ខត្តវិជ្ជា** *វិជ្ជាធ្វើជាគ្រូមើលនក្ខត្តឫក្ស*

**២១. អង្គវិជ្ជា** *វិជ្ជាធ្វើគ្រូទាយលក្ខណៈខ្លួនប្រាណ*

(*អសម្មោហវិលាសិនី ជាតកអភិនវដីកា ទុកនិបាត កល្យាណធម្ម-វគ្គ សតធម្មជាតក*)

# អាជីវបរិសុទ្ធិសីល

# សូចិមុខីសូត្រ

*(សមណសក្យបុត្រតែងឆាន់បិណ្ឌបាតប្រកបដោយធម៌)*

*សម័យមួយ ព្រះសារីបុត្តមានអាយុ គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ លំដាប់នោះ ព្រះសារីបុត្តមានអាយុ ស្លៀកស្បង់ ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅចូលកាន់ក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត លុះចូលទៅបិណ្ឌបាតតាមលំដាប់ច្រកក្នុងរាជគ្រឹះហើយ បានទៅគង់អាស្រ័យក្បែរជើងជញ្ជាំងមួយ ឆាន់ចង្ហាន់បិណ្ឌបាតនោះ ។ គ្រានោះ បរិព្វាជិកាឈ្មោះ***សូចិមុខី*** *បានចូលទៅរកព្រះសារីបុត្តមានអាយុ លុះចូលទៅដល់ហើយ បាននិយាយនឹងព្រះសារីបុត្តមានអាយុដូច្នេះថា*

*បពិត្រសមណៈ លោកឱនមុខឆាន់ឬអ្វី ?*

# អាជីវបរិសុទ្ធិសីល

(***ព្រះសារីបុត្តពោលថា***) *នៃប្អូនស្រី អាត្មាមិនមែនឱនមុខ ឆាន់ទេ ។*

(***បរិញ្វាជិកាសូចិមុខីពោលថា***) *បពិត្រសមណៈ បើដូច្នោះ លោកងើយមុខឆាន់ឬ ?*

(***ព្រះសារីបុត្តពោលថា***) *ម្នាលប្អូនស្រី អាត្មាមិនមែនងើយមុខឆាន់ទេ ។*

(***បរិញ្វាជិកាសូចិមុខីពោលថា***) *បពិត្រសមណៈ បើដូច្នោះ លោកបែរមុខទៅកាន់ទិសធំ ( ទាំង៤បួន) ឆាន់ឬអ្វី ?*

(***ព្រះសារីបុត្តពោលថា***)*ម្នាលប្អូនស្រី អាត្មាមិនមែនបែរមុខទៅកាន់ទិសធំឆាន់ទេ ។*

(***បរិញ្វាជិកាសូចិមុខីពោលថា***) *បពិត្រសមណៈ បើដូច្នោះ លោកងាកមុខទៅកាន់ទិសតូច ( ទាំង៤បួន) ឆាន់ឬអ្វី ?*

# អាជីវបរិសុទ្ធិសីល

(*ព្រះសារីបុត្តពោលថា*) ម្នាលប្អូនស្រី អាត្មាមិនមែនផ្ងាកមុខទៅកាន់ទិសតូចឆាន់ទេ ។

(***បរិញ្វាជិកាសូចិមុខីពោលថា***) ចុះព្រោះហេតុដូចម្តេច កាលដែលខ្ញុំសួរលោកថា បពិត្រសមណៈលោកឱនមុខឆាន់ឬអ្វី លោកឆ្លើយថា នែប្អូនស្រី អាត្មាមិនមែនឱនមុខ ឆាន់ទេ កាលដែលខ្ញុំសួរលោកថា បពិត្រសមណៈ បើដូច្នោះ លោកងើយមុខឆាន់ឬអ្វី លោកឆ្លើយថា នែប្អូនស្រី អាត្មាមិនមែនងើយមុខឆាន់ទេ កាលដែលខ្ញុំសួរលោកថា បពិត្រសមណៈ បើដូច្នោះ លោកបែរមុខទៅកាន់ទិសធំឆាន់ឬអ្វី លោកឆ្លើយថា នែប្អូនស្រី អាត្មាមិនមែនបែរមុខទៅកាន់ទិសធំឆាន់ទេ កាលដែលខ្ញុំសួរលោកថា បពិត្រសមណៈ បើដូច្នោះ លោកផ្ងាកមុខកាន់ទិសតូចឆាន់ឬអ្វី លោកឆ្លើយថា នែប្អូនស្រី អាត្មាមិនមែនផ្ងាកមុខទៅកាន់ទិសតូចឆាន់ទេ បពិត្រសមណៈ ចុះលោកឆាន់ដូចម្តេចវិញ ?

# អាជីវបរិសុទ្ធិសីល

(*ព្រះសារីបុត្តពោលថា*) នែប្អូនស្រី ពួកសមណព្រាហ្មណ៍ណានីមួយ ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា គឺវិជ្ជាមើលទាយចម្ការទីដី ម្នាលប្អូនស្រី សមណព្រាហ្មណ៍ពួកនេះ ហៅថា អ្នកឱនមុខចុះ ។

ម្នាលប្អូនស្រី ពួកសមណព្រាហ្មណ៍ណានីមួយ ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា គឺវិជ្ជាមើលខាងនក្ខត្តឫក្ស នែប្អូនស្រី សមណព្រាហ្មណ៍ពួកនេះ ហៅថា អ្នកងើយមុខចុះ ។

នែប្អូនស្រី ពួកសមណព្រាហ្មណ៍ណានីមួយ ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រោះការប្រកបរឿយ ៗ នូវទូតកម្ម និងការបញ្ជូនដំណឹង នែប្អូនស្រី សមណព្រាហ្មណ៍ពួកនេះ ហៅថា បែរមុខទៅកាន់ទិសធំចុះ ។

នែប្អូនស្រី ពួកសមណព្រាហ្មណ៍ណានីមួយ ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រោះ

# អាជីវបរិសុទ្ធិសីល

តិរច្ឆានវិជ្ជា គឺវិជ្ជាមើលខាងអង្គសម្បត្តិ ( ទាយលក្ខ-ណៈ) នៃប្អូនស្រី សមណព្រាហ្មណ៍ពួកនេះ ហៅថា បែរមុខទៅកាន់ទិសតូចឆាន់ ។

នៃប្អូនស្រី អាត្មាមិនមែនចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា គឺវិជ្ជាមើលទាយចម្ការទេ អាត្មាមិនមែនចិញ្ចឹមដោយមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា គឺវិជ្ជាមើលទាយនក្ខត្តឫក្ស អាត្មាមិនមែនចិញ្ចឹមដោយមិច្ឆាជីវៈ ព្រោះការប្រកបរឿយ ៗ នូវទូតកម្ម និងការបញ្ជូនដំណឹងទេ អាត្មាមិនមែនចិញ្ចឹមដោយមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា គឺវិជ្ជាទាយអង្គសម្បត្តិទេ អាត្មាតែងស្វែងរកកិក្ខាដោយធម៌ លុះស្វែងរកកិក្ខាបានដោយធម៌ហើយ ទើបឆាន់ ។

គ្រានោះ សូចិមុខីបរិព្វាជិកា ចេញអំពីច្រកចូលទៅកាន់ច្រក ចេញពីផ្លូវត្រឡែងកែង ចូលទៅកាន់ផ្លូវត្រឡែងកែង ក្នុងក្រុងរាជគ្រឹះ ប្រាប់គេយ៉ាងនេះថា

# អាជីវបរិសុទ្ធិសីល

សមណសក្យបុត្រទាំងឡាយ តែងឆាន់អាហារ ប្រកបដោយធម៌ សមណសក្យបុត្រទាំងឡាយ តែងឆាន់អាហារ ដែលមិនមានទោស អ្នកទាំងឡាយ ចូលប្រគេនដុំបាយដល់ពួក សមណសក្យបុត្រផងចុះ ។

ចប់ សូចិមុខីសូត្រ ៕

( សុត្តន្តបិដក សំយុត្តនិកាយ ខន្ធវគ្គ សារិបុត្តសំយុត្ត បិដកលេខ ៣៤ ទំព័រ ១៨៩)

## តិរច្ឆានវិជ្ជាក្នុងសូត្រនេះមាន ៣

១. វត្ថុវិជ្ជា វិជ្ជាមើលទាយចម្ការទីដី

២. នក្ខត្តវិជ្ជា វិជ្ជាមើលខាងនក្ខត្តឫក្ស

៣. អង្គវិជ្ជា វិជ្ជាមើលខាងអង្គសម្បត្តិ ( ទាយលក្ខណៈបុរសស្ត្រីជាដើម) ។

(អដ្ឋកថា)

# អាជីវបរិសុទ្ធិសីល

## សតធម្មជាតក

ព្រះសាស្តាកាលស្តេចគង់នៅវត្តជេតពន ទ្រង់ប្រារព្ធ**អនេសនៈ** (ការស្វែងរកបច្ច័យមិនប្រកបដោយធម៌) ២១ ប្រការ បានត្រាស់ព្រះធម្មទេសនានេះ មានពាក្យថា **តញ្ច អប្បំ** ដូច្នេះជាដើម ។

ក្នុងកាលនោះ ភិក្ខុទាំងឡាយជាច្រើនសម្រេចការចិញ្ចឹមជីវិតដោយអនេសនៈ ២១ ប្រការដែលមានសភាពបែបនេះ គឺ ***វេជ្ជកម្ម*** (ការធ្វើពេទ្យព្យាបាលជំងឺ) ***ទូតកម្ម*** (ការធ្វើទូតនាំដំណឹងរបស់គ្រហស្ថ) ***បហិណកម្ម*** (ការទទួលខ្លួនជាអ្នកបម្រើគ្រហស្ថឲ្យគេប្រើទៅមក ក្រៅអំពីការនាំដំណឹង) ***ជង្ឃបេសនិកៈ*** (ការបម្រើគ្រហស្ថដោយកម្លាំងស្មង) ***បិណ្ឌបដិបិណ្ឌៈ*** (ការឲ្យបង្អាន់បិណ្ឌបាតដល់គ្រហស្ថ ហើយស្វែងរកបរិភោគខ្លួនឯងជាខាងក្រោយ) ។ អនេសនៈនោះនឹង

## អាជីវបរិសុទ្ធិសីល

មានដាក់ច្បាស់ក្នុង**សាកេតជាតក**[១] ។ ព្រះសាស្តាបាន ដឹងនូវភាពនៃការចិញ្ចឹមជីវិតយ៉ាងនោះ របស់ភិក្ខុទាំង នោះហើយ ទ្រង់ត្រិះរិះថា ឥឡូវនេះ ភិក្ខុទាំងឡាយជា ច្រើន សម្រេចការចិញ្ចឹមជីវិតដោយអនេសនៈ បើភិក្ខុ ទាំងឡាយនោះសម្រេចការចិញ្ចឹមជីវិតយ៉ាងនេះ នឹង មិនរួចផុតអំពីភាពជាយក្ស នឹងមិនរួចផុតអំពីភាពជា ប្រេត នឹងកើតជាគោនាំរទេះ នឹងកាន់យកបដិសន្ធិក្នុង នរក តថាគតគួរនឹងសម្ដែងធម្មទេសនាមួយ តាម អធ្យាស្រ័យរបស់ខ្លួន ដែលជាបដិភាណរបស់ខ្លួន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខដល់ភិក្ខុ ទាំងឡាយនោះ ដូច្នេះហើយ ទ្រង់ឲ្យភិក្ខុសង្ឃប្រជុំគ្នា ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ

---

[១]. *(ក្នុងសាកេតជាតកទាំងពីរមិនឃើញមាននិយាយអំពីអនេសនៈនេះទេ ប្រហែលជាមានក្នុងជាតកដទៃ)។*

# អាជីវបរិសុទ្ធិសីល

មិនគួរញុំាងបច្ច័យឲ្យកើតដោយអនេសនៈ ២១ ប្រការឡើយ ព្រោះបិណ្ឌបាតដែលកើតដោយអនេសនៈប្រាជកដូចដុំដែកក្ដៅ មានឧបមាដូចថ្នាំពិសដ៏ខ្លាំងក្លា ។ ពិតមែនហើយ ឈ្មោះថា អនេសនៈនោះ គឺព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ សាវកពុទ្ធគប្បីតិះដៀល និងបានជំទាស់ហើយ ។ សេចក្ដីរីករាយក្ដី សេចក្ដីសោមនស្សក្ដី របស់អ្នកដែលបរិភោគបិណ្ឌបាត ដែលកើតដោយអនេសនៈនោះ រមែងមិនមាន ។ ក្នុងសាសនារបស់តថាគត (ចាត់ទុក) បិណ្ឌបាតដែលកើតឡើងយ៉ាងនោះ ប្រៀបដូចជាអាហារសំណល់ពីមនុស្សចណ្ឌាលដែលដូចជា ការបរិភោគអាហារសំណល់ពីមនុស្សចណ្ឌាល របស់សតជម្មមាណពដូច្នោះ ដូច្នេះហើយព្រះអង្គបាននាំអតីតនិទានមកថា

# អាជីវបរិសុទ្ធិសីល

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តសោយរាជសម្បត្តិក្នុងនគរពារាណសី ព្រះពោធិសត្វកើតក្នុងកំណើតជាមនុស្សចណ្ឌាល កាលចម្រើនវ័យធំហើយ ក្នុងថ្ងៃមួយ បានកាន់យកអង្ករជាស្បៀង និងកញ្ចប់បាយ ហើយធ្វើដំណើរចេញទៅ ដោយករណីយកិច្ចយ៉ាងណាមួយ ។ ក្នុងកាលនោះ មានមាណពម្នាក់ឈ្មោះ សតធម្មៈ កើតក្នុងត្រកូលព្រាហ្មណមហាសាល ក្នុងនគរពារាណសី ។ សូម្បីសតធម្មមាណពនោះក៏ធ្វើដំណើរទៅដោយករណីយកិច្ចយ៉ាងណាមួយដែរ តែគេនោះមិនកាន់យកអង្ករជាស្បៀង និងកញ្ចប់បាយឡើយ ជនទាំងពីរនោះបានទៅជួបគ្នាត្រង់ផ្លូវធំ ។ មាណពសួរព្រះពោធិសត្វថា អ្នកមានជាតិអ្វី ? ព្រះពោធិសត្វពោលថា ខ្ញុំជាមនុស្សចណ្ឌាល ហើយសួរមាណពថា ចុះអ្នកមានជាតិអ្វីដែរ ?

# អាជីវបរិសុទ្ធិសីល

មាណពពោលថា ខ្ញុំជាឧទិច្ចព្រាហ្មណ៍ ។ ជនទាំងពីរពោលថា ល្អហើយ យើងនឹងទៅ ហើយបានធ្វើដំណើរទៅជាមួយគ្នា ។ ក្នុងវេលាបរិភោគអាហារពេលព្រឹក ព្រះពោធិសត្វអង្គុយកន្លែងដែលមានទឹករកបានងាយ លាងដៃ រួចស្រាយកញ្ចប់បាយហើយពោលថា នៃមាណព ចូរមកបរិភោគបាយ (ជាមួយខ្ញុំ) ។ មាណពពោលថា នៃមនុស្សចណ្ឌាលចង្រៃ សេចក្តីត្រូវការដោយបាយ របស់ខ្ញុំ មិនមាន ។ ព្រះពោធិសត្វពោលថា ល្អហើយចឹង ធ្វើមិនឲ្យកញ្ចប់បាយជារបស់សល់ ដួសបាយល្មមមួយចម្អែត ដាក់លើស្លឹកឈើដទៃហើយចងកញ្ចប់ ទុកកន្លែងមួយ រួចទើបបរិភោគ និងផឹកទឹក មានដៃនិងជើងលាងហើយ កាន់យកស្បៀងនិងបាយដែលសល់ ពោលថា នៃមាណពយើងនឹងទៅទៀត ហើយក៏ចេញដំណើរបន្ត ។

# អាជីវបរិសុទ្ធិសីល

ព្រះពោធិសត្វនិងមាណពនោះធ្វើដំណើរទៅរហូតអស់ពេលថ្ងៃ ដល់វេលាល្ងាច ជនទាំងពីរមុជទឹកក្នុងទីដែលមានទឹកល្អ ហើយឡើងមក ។ ព្រះពោធិសត្វអង្គុយកន្ទេងជាសុខមួយ ស្រាយកញ្ចប់បាយហើយមិនបានហៅមាណពដូចមុនទេ ប្រារព្ធនឹងបរិភោគតែម្តង ។ មាណពកាលនឿយហត់ដោយការធ្វើដំណើរផ្លូវអស់ថ្ងៃ កើតសេចក្តីឃ្លាន ឈរសម្លឹងមើលដោយគិតថា បើមនុស្សចណ្ឌាលឲ្យបាយដល់យើង យើងនឹងបរិភោគ ។ ចំណែកព្រះពោធិសត្វបាននិយាយអ្វីឡើយ គិតតែបរិភោគតែម្យ៉ាង ។ មាណពគិតថា មនុស្សចណ្ឌាលនេះ មិននិយាយនឹងយើង គង់នឹងបរិភោគទាំងអស់ យើងគួរតែដណ្តើមយកអាហារនោះ គៀរអាហារដែលនៅខាងលើបោះចោល ហើយ

## អាជីវបរិសុទ្ធិសីល



បរិភោគអាហារដ៏សេស ។ មាណពនោះក៏បានធ្វើយ៉ាងនោះ ហើយបរិភោគបាយសំណល់ ។

លំដាប់នោះ ពេលបរិភោគបាយរួចភ្លាម មាណពកើតសេចក្តីក្តៅក្រហាយ ស្តាយក្រោយដ៏ខ្លាំងថា អញបានធ្វើអំពើមិនសមគួរដល់ជាតិ គោត្រ ត្រកូល និងប្រទេសរបស់ខ្លួន អញបានបរិភោគអាហារដែលសល់ពីមនុស្សចណ្ឌាល ។ ពេលនោះ អាហារដែលលាយដោយឈាម បានក្អួតចេញពីមាត់របស់មាណពនោះ ។ មាណពកាលបរិទេវនាការ ព្រោះភាពជាអ្នកមានសេចក្តីសោកដ៏ខ្លាំងថា អញបានធ្វើកម្មដែលមិនសមគួរ ព្រោះហេតុនៃអាហារបន្តិចបន្តួច ដូច្នេះហើយ ទើបពោលគាថាទី ១ ថា

## អាជីវបរិសុទ្ធិសីល

តញ្ចា អប្បញ្ចា ឧច្ចិដ្ឋំ,
តញ្ចា តិកេច្ចន ជោ អទា;
សោហំ ព្រាហ្មណជាតិកោ,
យំ កុត្តំ តម្បិ ឧគ្គតំ។

*(អាហារណាដែលបានបរិភោគហើយ) បាយនោះជារបស់តិចផង សល់ដែលផង បុរសចណ្ឌាល បានឲ្យបាយនោះដល់យើងដោយសេចក្តីពិបាក យើងប្រកបដោយជាតិជាព្រាហ្មណ៍ អាហារណាដែលយើងបានបរិភោគហើយ អាហារនោះឯង ក៏ក្អួតចេញមក ។*

*គាថានោះ មានសេចក្តីសង្ខេបដូចនេះថា អាហារណាដែលយើងបរិភោគហើយ អាហារនោះជារបស់តិចផង ជាសំណល់ផង មនុស្សចណ្ឌាលនោះ មិនបានឲ្យអាហារនោះដល់យើងដោយសេចក្តីពេញចិត្តរបស់ខ្លួនទេ គឺយើងដណ្តើមយកមក ទើបឲ្យមក*

# អាជីវបរិសុទ្ធិសីល

ដោយសេចក្ដីលំបាក យើងនោះ ជាព្រាហ្មណ៍មាន ជាតិបរិសុទ្ធ អាហារណាដែលយើងបរិភោគហើយ អាហារនោះទើបក្អួតចេញជាមួយនឹងឈាម ។

មាណពបរិទេវៈយ៉ាងនេះហើយ គិតថា ឥឡូវនេះ យើងបានធ្វើកម្មដែលមិនសមគួរមានសភាពបែបនេះ នឹងមានប្រយោជន៍អ្វីដោយជីវិត ដូច្នេះហើយ ក៏ចូលទៅកាន់ព្រៃ មិនឲ្យអ្នកណាឃើញខ្លួនគេឡើយ ហើយដល់នូវមរណៈយ៉ាងអនាថា ។

ព្រះសាស្ដាបានសម្ដែងអតីតនិទាននេះហើយ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សតធម្មមាណពបរិភោគអាហារ ដែលសល់ពីមនុស្សចណ្ឌាល ព្រោះភាពជាអ្នកបរិភោគភោជនដែលមិនសមគួរដល់ខ្លួន ទើបមិនបានសេចក្ដីរីករាយ និងសោមនស្ស យ៉ាងណា បុគ្គលណាបួសហើយក្នុង

## អាជីវបរិសុទ្ធិសីល

សាសននេះ កាលសម្រេចការចិញ្ចឹមជីវិតដោយអនេសនៈ បរិភោគបច្ច័យដែលបានមកហើយនោះ ក៏យ៉ាងនោះដែរ សេចក្តីរីករាយ និងសោមនស្សរមែងមិនកើតឡើង ព្រោះភាពនៃជីវិតរបស់បុគ្គលនោះ ត្រូវព្រះពុទ្ធហាមឃាត់ និងតិះដៀល ដូច្នេះហើយ ព្រះអភិសម្ពុទ្ធទើបត្រាស់ព្រះគាថាទី ២ ថា

**ឃរំ ជម្ពុំ ធិរំកាត្វា,**
**យោ អជម្មេន ជីវតិ,**
**សតជម្មោវ លោកេន,**
**លទ្ធេនបិ ន ឆេ្ដតិ។**

ភិក្ខុណាលះបង់នូវធម៌ គឺអាជីវបារិសុទ្ធិសីល ហើយចញ្ចឹមជីវិតដោយខុសធម៌យ៉ាង នេះ ភិក្ខុនោះមិនត្រេកអរ ដោយលាភដែលខ្លួនបានហើយ ដូចជាសតធម្មមាណព ។

# **អាជីវបរិសុទ្ធិសីល**

*បណ្ដាបទទាំងនោះ បទថា* **ជម្មំ** *បានដល់ ធម៌ គឺ អាជីវបរិសុទ្ធិសីល (សីលដែលមានសេចក្ដីបរិសុទ្ធ ព្រោះការចិញ្ចឹមជីវិតត្រឹមត្រូវ) ។ បទថា* **ជិរំកត្វា** *សេចក្ដីថា លះបង់ បោះចោលហើយ ។ បទថា* **អជ-ម្មេន** *សេចក្ដីថា មិច្ឆាជីវៈ ពោលគឺដោយអនេសនៈ ២១ ។ បទថា* **សតជម្មោ** *បានដល់ ជាឈ្មោះនៃមាណពនោះ បាឋៈថា សន្តធម្មោ ដូច្នេះក៏មាន ។ បទថា* **ជ ជន្ទតិ** *សេចក្ដីថា សតធម្មមាណពមិនត្រេកអរដោយលោភៈនោះថា យើងបានអាហារដែលសល់ពីមនុស្សចណ្ឌាល យ៉ាងណា សូម្បីកុលបុត្រដែលបួសក្នុងសាសននេះ កាលបរិភោគលាភដែលបានមកដោយអនេសនៈរមែងមិនរីករាយ មិនត្រេកអរ ក៏យ៉ាងនោះដែរ ជាអ្នកដល់សេចក្ដីទោមនស្សថា អញរស់នៅដោយការចិញ្ចឹមជីវិតដែលព្រះពុទ្ធតិះដៀល ។ ព្រោះហេតុនោះ បុគ្គលដែលសម្រេចការចិញ្ចឹមជីវិតដោយ*

# អាជីវបរិសុទ្ធិសីល

*អនេសនៈ ចូលព្រៃស្ងាប់យ៉ាងអនាថាប្រសើរជាង ដូចជាសតធម្មមាណពដូច្នោះ ។*

*ព្រះសាស្ដាបាននាំព្រះធម្មទេសនានេះមកហើយ ទ្រង់ប្រកាសសច្ចៈទាំងឡាយ និងប្រជុំជាតកក្នុងកាលជាទីបញ្ចប់នៃសច្ចៈ ភិក្ខុទាំងឡាយជាច្រើនបានដល់នូវសោតាបត្តិផលជាដើម ។*

**តទា មាណវោ អានន្ទោ អហោសិ** *មាណពក្នុងកាលនោះ បានមកជាអានន្ទ ។*

**អហមេវ ចណ្ឌាលបុត្តោ អហោសឹ** *បុត្ររបស់មនុស្សចណ្ឌាល គឺតថាគតនេះឯង ។*

*ចប់ សតធម្មជាតក ៕*

*( ជាតកដ្ឋកថា សុត្តន្តបិដក ខុទ្ទកនិកាយ ជាតក ទុកនិបាត កល្យាណធម្មវគ្គ បិដកលេខ ៥៨ ទំព័រ ៨៦)*



**ឧត្តិដ្ឋេ នប្បមជ្ជេយ្យ, ធម្មំ សុចរិតំ ចរេ;**

**ធម្មចារី សុខំ សេតិ, អស្មឹ លោកេ បរម្ហិ ច។**

*បុគ្គលមិនគួរប្រមាទក្នុងដុំបាយដែលខ្លួនគប្បីក្រោកឡើងទទួល គប្បីប្រព្រឹត្តធម៌ឲ សុចរិត បុគ្គលអ្នកប្រព្រឹត្តធម៌ជាប្រក្រតី រមែងដេកជាសុខ ក្នុងលោកនេះផង ក្នុងលោកខាងមុខផង*

*( សុត្តន្តបិដក ខុទ្ទកនិកាយ ធម្មបទ លោកវគ្គ បិដកលេខ ៥២ ទំព័រ ៥៧ )*